ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៤៦៤ សហវ.ពន

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលអាករលើការស្នាក់នៅ

យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ និងផ្អែកតាមប្រកាសលេខ ៣៨០ សហវ.ពដ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ និងប្រកាសលេខ ៦០១ សហវ.ពដ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការពន្យារពេលការអនុវត្តន៍អាករលើការស្នាក់នៅ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបជូនដំណឹងដល់សាធារណជនទាំងអស់ ជាពិសេសម្ចាស់សណ្ឋាគារ ឬអ្នកតំណាងឱ្យបានជ្រាបថា ការប្រមូលអាករលើការស្នាក់នៅត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ សំរាប់ជាគុណប្រយោជន៏ដល់ថវិកាខេត្ត-ក្រុង ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាង ដែលត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ឬ របបម៉ៅការ មានកាតព្វកិច្ចប្រមូលអាករលើការស្នាក់នៅពីភ្ញៀវ និងបង់ប្រាក់អាករនេះជូនរដ្ឋបាលសារពើពន្ធ ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់អាករប្រចាំខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។ ចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវបង់ប្រាក់អាករនេះជារៀងរាល់ខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ពីខែ ដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។

អាករលើការស្នាក់នៅត្រូវបានកំណត់យកតាមអត្រា ២ ភាគរយ លើថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារ ដោយរួមបញ្ចូលទាំងពន្ធ-អាករ និង បន្ទុកសេវាផ្សេងៗ (Service Charge) លើកលែងតែអាករលើការស្នាក់នៅខ្លួនឯង និងអាករលើតម្លៃបន្ថែម ។

ក្នុងករណីអ្នកជាប់ពន្ធមិនបានប្រមូល និងមិនបានដាក់លិខិប្រកាសបង់អាករលើការស្នាក់នៅ អ្នកជាប់ពន្ធនោះត្រូវរងទទួលទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដូចមានចែងក្នុងផ្នែកទី៩-១០ និង១១ ជំពូកទី៩ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីដែលជាម្ចាស់សណ្ឋាគារ ឬអ្នកតំណាង មេត្តាជ្រាប និង អនុវត្តបទប្បញ្ញត្តិអាករលើការស្នាក់នៅនេះឱ្យមានប្រសិទ្ធភាព ។

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798